គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ
បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា
Regulate, Supervise, and Develop Trust Sector
in the Kingdom of Cambodia

និយ័តករបរធនបាលកិច្ច
Trust Regulator

លេខ៤៥ ចេញផ្សាយថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២
No. 45 Released on 13 May, 2022

# អត្ថបទប្រចាំសប្តាហ៍ | Weekly Article

## តើការតែងតាំង ឬផ្លាស់ប្តូរបរធនបាល ឬ បរធនបាលជំនួស ត្រូវធ្វើដូចម្តេចទើបស្របច្បាប់ស្តីពីបរធនបាលកិច្ច?



រូបភាព | Picture: https://www.google.com/search?q=successor+trustee&tbm=

បរធនបាល ដែលបានទទួលអាជ្ញាបណ្ណ/ការអនុញ្ញាតពី **ន.ប.ធ** ទើបអាចត្រូវបានជ្រើសតាំងជាបរធនបាលក្នុងការគ្រប់គ្រង ចាត់ចែង និងថែរក្សាទ្រព្យសម្បត្តិបរធនបាលកិច្ច។ បរធនបាល ដែលត្រូវបានតែងតាំងឱ្យធ្វើប្រតិបត្តិការបរធនបាលកិច្ចណាមួយ ត្រូវស្នើសុំការអនុញ្ញាតបង្កើត និងចុះបញ្ជីបរធនបាលកិច្ចពីអគ្គនាយកនៃ **ន.ប.ធ** ក្នុងនាមបរធនបាលទាយក តាមនីតិវិធីកំណត់ក្នុងច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងវិស័យបរធនបាលកិច្ច។

បរធនបាលទាយក ឬអ្នកផ្តល់វិភាគទានបរធនបាលកិច្ចអាចតែងតាំងបរធនបាលមួយ ឬច្រើន សម្រាប់បរធនបាលកិច្ចមួយ ដូចមានចែងក្នុងមាត្រា២០ នៃច្បាប់ស្តីពីបរធនបាលកិច្ច។ ដូច្នេះ បរធន-បាលដែលកំពុងគ្រប់គ្រង ចាត់ចែង និងថែរក្សាបរធនបាលកិច្ចនោះក៏អាចត្រូវបានធ្វើការផ្លាស់ប្តូរ ឬជំនួស ស្របតាមលក្ខខណ្ឌដូចខាងក្រោម÷

-ករណីដែលបរធនបាលជារូបវន្តបុគ្គល បរធនបាលនេះត្រូវបានជំនួស÷

**ក-** ជាស្វ័យប្រវត្តិ នៅពេលទទួលមរណភាព, អសមត្ថភាពផ្លូវកាយ ឬផ្លូវចិត្ត, ត្រូវបានប្រកាសដោយអាជ្ញាធរមានសមត្ថកិច្ចថាក្ស័យធន, ប្រព្រឹត្តបទល្មើសមជ្ឈិមឬឧក្រិដ្ឋ, ឬតាមលក្ខខណ្ឌផ្សេងទៀត ដែលកំណត់ដោយបទប្បញ្ញត្តិជាធរមាន។

**ខ-** តាមសេចក្តីសម្រេចភាគច្រើនដាច់ខាតរបស់បរធនបាលទាំងអស់, នៅពេលដែលបរធនបាលចូលនិវត្តន៍, បដិសេធមិនបំពេញការងារ, ឬមិនសក្តិសមបំពេញការងារ។

-ករណីដែលបរធនបាលជានីតិបុគ្គល បរធនបាលនេះត្រូវបានជំនួសនៅពេល ដែលបរធនបាលបានបញ្ឈប់សកម្មភាពរបស់ខ្លួន ហើយត្រូវបានជម្រះបញ្ជី ឬត្រូវបានរំលាយ។

នីតិវិធីនៃការផ្លាស់ប្តូរ/ជំនួស÷ បរធនបាលទាយក ឬអ្នកផ្តល់វិភាគទានបរធនបាលកិច្ច ត្រូវធ្វើការជ្រើសរើសបេក្ខភាពបរធនបាល ដែលទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតពី **ន.ប.ធ**។ បរធនបាលអាចត្រូវបានជំនួស តាមលក្ខខណ្ឌ និងនីតិវិធីផ្សេងទៀត ដែលមានចែងក្នុងលិខិតបរធនបាលកិច្ច ឬបទប្បញ្ញត្តិជាធរមាន។ បញ្ញត្តិករពាក់ព័ន្ធអាចចេញសេចក្តីសម្រេចតែងតាំងបរធនបាលជំនួស និងត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកនិយ័តករបរធនបាលកិច្ច។

**អត្ថបទ÷ ផាប់ រ៉ដូ**

**ឯកសារយោង**

- ច្បាប់ស្តីពីបរធនបាលកិច្ច (២០១៩)
- ប្រកាសស្តីពី វិធានក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច (២០២២)

ប្រកាសបដិសេធ÷ ទស្សនៈនៅក្នុងអត្ថបទនេះជាទស្សនៈរបស់អ្នកនិពន្ធ។ ទស្សនៈនៅក្នុងអត្ថបទនេះមិនមែនជាទស្សនៈរបស់និយ័តករបរធនបាលកិច្ចទេ។
Disclaimer: The opinions expressed in this article are those of the authors. They do not purport to reflect the opinions or views of the Trust Regulator.

# How to appoint or replace the trustee or substitute trustee in line with the law on trust?



រូបភាព | Picture: https://www.google.com/search?q=successor+trustee&tbm=

**The Trustee** that obtained a license/approval from Trust Regulator will be subjected to be nominated as Trustee to manage, administer and retention of the Trust property. On behalf of Trustor, nominated Trustee shall apply for approval from Director General of the Trust Regulator to establish and registration in Cambodia in accordance with relevant Law and Regulations. in favor of the Beneficiaryby the terms of the Trust Instrument or applicable regulations.

The trustor/ Contributor of Trust fund may nominate one or more Trustee for a Trust according to article 20 of Trust Law. So, in a period of Trust functioning, Trustee that is managing, administering and retaining trust property can be changed or replaced as following conditions:

-Individual Trustee may replace:

A- Automaticcally when he/she dies, his / her physical or mental incapacity, bankruptcy which declared by the competent authority, commit a crime or an offense, or under other conditions which determined by the provisions of the relevant regulation.

B- By the absolute majority decision of all the trustees, when the trustee retire, refuse to perform their duties, or are not worthy to perform their duties.

- Trustee Company: Trustee company shall be replaced when Trustee company's operation ceased its activities and is liquidated or dissolved.

The Trustee Replacement procedure: The trustor/ the Contributor of Trust Fund shall select the candidature of Trustees who have obtained the license/approval of the Trust Regulator. Trustee may be replaced in accordance with other conditions and procedure which stipulated in Trust deed or regulations. The competent regulator may decide to appoint a replacement Trustee, in this case the regulator shall prior notify by written to the Trust Regulator.

**Article: RADO PHAP**

**References:**

- Law on Trust (2019)
- Prakas on Rules on the Management, Organization and the Functioning of Trust (2022)

ប្រកាសបដិសេធ៖ ទស្សនៈនៅក្នុងអត្ថបទនេះជាទស្សនៈរបស់អ្នកនិពន្ធ។ ទស្សនៈនៅក្នុងអត្ថបទនេះមិនមែនជាទស្សនៈរបស់និយ័តករបរធនបាលកិច្ចទេ។
Disclaimer: The opinions expressed in this article are those of the authors. They do not purport to reflect the opinions or views of the Trust Regulator.